# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣៨៣២ ព.ណ.ករ.ល

ថ្ងៃសុក្រ ១កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០២២

**ជម្រាបមក**

**លោកប្រធានក្រុមហ៊ុន ពន្លឺអលង្ការ**

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលទឹកដោះគោម៉ាក BEAR BRAND ដែលមានភ្ជាប់ប្រភេទ និងចំណុះមកជាមួយ របស់ក្រុមហ៊ុន **ពន្លឺ អលង្ការ** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **ពន្លឺ អលង្ការ** ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Société des Produits Nestlé S.A ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Nestle (Thai) Ltd. ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៦៣៧០/០២ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានក្រុមហ៊ុនថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលទឹកដោះគោពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **ពន្លឺ អលង្ការ** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Société des Produits Nestlé S.A ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតបន្តសុពលភាពកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Société des Produits Nestlé S.A ដែលជាម្ចាស់ម៉ាក។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

***ចម្លងជូន:***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

# បញ្ជី

## ប្រភេទ និងចំណុះទំនិញកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ

## ទឹកដោះគោម៉ាក

| ល.រ | ឈ្មោះ និងចំណុះ |
|---|---|
| 1 | BEAR BRAND Sterilized Milk 8 (12x140ml) |
| 2 | BEAR BRAND Sterilized Low Fat Milk 8 (12x140ml) |
| 3 | BEAR BRAND Sterilized Folate Milk 8 (12x140ml) |
| 4 | BEAR BRAND Sterilized Gold White Malt 6 (4x140ml) |
| 5 | BEAR BRAND Sterilized Gold White Kidney Beans 6 (4x140ml) |